**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ : ០១១ /២៥ ក.ប/ស.ជ.ណ.ស.ជ.ក**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការដាក់ពាក្យធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព ដើម្បីទទួលបានគុណវុឌ្ឍិជាតិ សម្រាប់ឆ្នាំ២០២៥

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានសិក្សាសាធារណៈ ឯកជន អង្គការ សមាគម ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន សិក្ខាកាម សិស្ស និស្សិត សាធារណជន ជាពិសេស កម្មករនិយោជិតទាំងអស់ឱ្យបានជ្រាបថា ក្រសួងបានបង្កើតកម្មវិធីធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន (ទ.ស.ម) លើសមត្ថភាពដែលទទួលបានពីការអប់រំ ការបណ្តុះបណ្តាលមិនផ្លូវការ ការសិក្សាក្រៅប្រព័ន្ធ និងសមត្ថភាពដែលទទួលបានពីបទពិសោធនៅកន្លែងការងារ ដើម្បីទទួលបានគុណវុឌ្ឍិជាតិ សម្រាប់ឆ្នាំ២០២៥។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន អង្គការ សមាគម ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន សិក្ខាកាម សិស្ស និស្សិត កម្មករនិយោជិត និងសាធារណជនទាំងអស់ដែលមានបំណងចង់ធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព អាចចុះឈ្មោះតាមប្រព័ន្ធអនឡាញ https://tvet-erpl.com/home ឬអាចមកដាក់ពាក្យដោយផ្ទាល់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ម៉ោងធ្វើការ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៧:០០នាទីព្រឹក ដល់ម៉ោង ៥:៣០នាទីល្ងាច នៅមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលបានចុះបញ្ជិកា។

ថ្ងៃចន្ទ ៣កើត ខែបឋមាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

"ស្កេនដើម្បីចុះឈ្មោះ" "ទីតាំងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព"

**កន្លែងទទួល៖**
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- គ្រឹះស្ថាន អ.ប.វ. ក្រោមឱវាទ
- ឯកសារ កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*